# ប្រវត្តិ និងកម្មវិធីរបស់គម្រោង ការសិក្សាតាមរយៈអេឡិចត្រូនិច

កម្មវិធីការសិក្សាតាមរយៈអេឡិចត្រូនិច ត្រូវបានផ្តួចផ្តើមឡើង ដោយអង្គការវិទ្យាស្ថានបើកទូលាយ នាឆ្នាំ ២០០៦ ។

## ១ គោលបំណងរបស់កម្មវិធី

កម្មវិធីសិក្សាតាមរយៈអេឡិចត្រូនិច របស់អង្គការវិទ្យាស្ថាន បើកទូលាយ មានគោលបំណង ផ្តល់នូវចំណេះដឹង អំពីរបៀបបង្កើត និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច (E-learning Know-how) តាមរយៈ៖ ការផ្តល់វគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រង E-learning និងផ្តល់ជូននូវ ប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System) ជាភាសាខ្មែរ ។ កម្មវិធីនេះ នឹងផ្តល់នូវការកសាងសមត្ថភាព និងបទពិសោធន៍អនុវត្តផ្ទាល់ ជូនដល់ស្ថាប័នសិក្សាអប់រំនានា ក្នុងប្រទេសកម្ពុជា ដើម្បីអោយស្ថាប័នទាំងនោះ អាចបង្កើត និងគ្រប់គ្រងវគ្គសិក្សាតាមរយៈអេឡិចត្រូនិច ដោយខ្លួនឯងបាន ។

## ២ សកម្មភាពរបស់កម្មវិធី

កម្មវិធីសិក្សាតាមរយៈអេឡិចត្រូនិច អនុវត្តនូវសកម្មភាពសំខាន់ៗ ចំនួន៤គឺ៖

- ការផ្តល់ជូននូវ ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច ជាភាសាខ្មែរ
- ការផ្តល់វគ្គបណ្តុះបណ្តាលតាមរយៈអេឡិចត្រូនិច
- ការសិក្សាស្រាវជ្រាវអំពី ការសិក្សាតាមរយៈអេឡិចត្រូនិច
- និងការចងក្រងជាបណ្តាញ អ្នកជំនាញការប្រើប្រាស់ និងគ្រប់គ្រងការសិក្សាតាមរយៈ អេឡិចត្រូនិច

### ក/ ការផ្តល់ជូននូវ ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច ជាភាសាខ្មែរ

កម្មវិធីរបស់យើងក៏បាននឹងកំពុងធ្វើការបកប្រែ មកជាភាសាខ្មែរ នូវប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិចមួយ ដែលមានឈ្មោះថា Moodle ។ Moodle គឺជាកម្មវិធីកូដបើកចំហ និងឥតគិតថ្លៃ (Free and Open Source Software) ដែលបើកទូលាយដល់ការយកប្រព័ន្ធនេះមកកែប្រែ ឬប្រើប្រាស់ ឬចែកចាយបន្ត ។

តាមស្ថិតិ របស់គម្រោង Moodle បច្ចុប្បន្ន ប្រព័ន្ធនេះ ត្រូវបានប្រើប្រាស់ ដោយតំបន់បណ្តាញ (Websites) នៃស្ថាប័នអប់រំនានា ជាងបីម៉ឺន នៅទូទាំងពិភពលោក ដែលតួរលេខនេះ កំពុងតែកើនឡើងជាលំដាប់ ។ ជាមួយ Moodle យើងអាចបង្កើតវគ្គសិក្សាជាលក្ខណៈអេឡិចត្រូនិច បានយ៉ាងងាយស្រួល និងឆាប់រហ័ស ។ ក្នុងវគ្គសិក្សានីមួយៗ យើងអាចបន្ថែមនូវធនធាន និងសកម្មភាពជាច្រើន (Learning Resources and Activities) ដើម្បីជាជំនួយដល់ការ

បង្រៀនរបស់គ្រូ ក៏ដូចជាការសិក្សារបស់សិស្ស ។ ធនធាន និងសកម្មភាពទាំងនោះ អាចមានដូចជា ៖

- មេរៀន ឯកសារយោង ឬ អត្ថបទស្វែងយល់ផ្សេងៗ ដោយអាចរួមបញ្ចូលផងដែរ នូវរូបភាព សំឡេង ឬវីដេអូនៃសកម្មភាពផ្សេងៗ ។ល។
- សំណួរ ឬកម្រងសំណួរសម្រាប់មេរៀន (Question ឬ Quiz) កិច្ចការ (Assignment) កិច្ចការធ្វើនៅផ្ទះ (Homework) ។ល។
- មធ្យោបាយទំនាក់ទំនង ដើម្បីជួយជំរុញដល់ការចូលរួម និងការពិភាក្សាស្រាវជ្រាវរបស់សិស្ស មានដូចជា ៖ វេទិកាពិភាក្សា (Discussion Forum) ការសន្ទនា (Chat) កំណត់ហេតុលើបណ្តាញ (Blog) វិគី (Wiki) ទិនានុប្បវត្តិ (Journal) ព្រមទាំងមធ្យោបាយផ្សេងៗទៀតជាច្រើន ។

## ខ/ ការផ្តល់វគ្គបណ្តុះបណ្តាលតាមរយៈអេឡិចត្រូនិច

បច្ចុប្បន្ននេះ កម្មវិធីយើងបាននឹងកំពុងសិក្សា និងរៀបចំនូវមេរៀន ស្តីអំពីរបៀបបង្កើត និងគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច ។ បន្ទាប់ពីរៀបចំមេរៀន និងការបកប្រែកម្មវិធីប្រព័ន្ធគ្រប់គ្រងការសិក្សា អង្គការក៏នឹងរៀបចំផ្តល់វគ្គបណ្តុះបណ្តាល ដល់ស្ថាប័នសិក្សាអប់រំនានា អំពីរបៀបបង្កើត និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច និងរបៀបប្រើប្រាស់និងគ្រប់គ្រងកម្មវិធី ប្រព័ន្ធគ្រប់គ្រងការសិក្សា ។

វគ្គសិក្សាទាំងនោះមានដូចជា៖

<u>របៀបបង្កើត និងគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច</u>

1. វិធីសាស្ត្រក្នុងការរៀបចំវគ្គបណ្តុះបណ្តាល (Instructional Design)
2. ការធ្វើមេរៀន (Content Development)
3. ស្វែងយល់អំពីបច្ចេកវិទ្យា នៃការសិក្សាតាមរយៈអេឡិចត្រូនិច (E-learning Technology)
4. ការគ្រប់គ្រងគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិច (E-learning Project Management)
5. ការបង្រៀន នៃការសិក្សាតាមរយៈអេឡិចត្រូនិច (Tutoring & Support of Virtual Learning Environment)
6. យុទ្ធសាស្ត្រ នៃការសិក្សាតាមរយៈអេឡិចត្រូនិច (E-learning Strategy)

<u>របៀបប្រើប្រាស់ និងគ្រប់គ្រងកម្មវិធី ប្រព័ន្ធគ្រប់គ្រងការសិក្សា</u>

7. របៀបប្រើប្រាស់ និងគ្រប់គ្រង ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច សម្រាប់អ្នកគ្រប់គ្រងប្រព័ន្ធ (System Administrators)
8. របៀបប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច សម្រាប់អ្នកគ្រប់គ្រងវគ្គសិក្សា (Course Administrators)
9. របៀបប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច សម្រាប់គ្រូបង្រៀន (Trainers)

10. របៀបប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច សម្រាប់សិស្ស (Students) ។

មេរៀនស្តីអំពី របៀបបង្កើត និងគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច ជាផ្នែកមួយនៃកិច្ចសហការ រវាងអង្គការវិទ្យាស្ថានបើកទូលាយ និង International Capacity Building – Germany ដែលជាស្ថាប័នមួយនៃប្រទេសអាល្លឺម៉ង់ ដែលមានជំនាញក្នុងការកសាងសមត្ថភាពជាលក្ខណៈអន្តរជាតិ និងមានបទពិសោធន៍ និងមានធនធានជំនាញក្នុងការគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច ។

### គ/ ការសិក្សាស្រាវជ្រាវ អំពីការសិក្សាតាមរយៈអេឡិចត្រូនិច

កម្មវិធីនេះ នឹងធ្វើការសិក្សាស្រាវជ្រាវអំពី ការវិវត្ត និងស្ថានភាពនៃការប្រើប្រាស់ ការសិក្សាតាមរយៈអេឡិចត្រូនិច ដោយសហការជាមួយ ស្ថាប័នសិក្សាអប់រំ និងនិស្សិតដែលពាក់ព័ន្ធ ក្នុងការស្វែងយល់អំពីការប្រើប្រាស់ កត្តាប្រឈម និងផលប្រយោជន៍ នៃការសិក្សាតាមរយៈអេឡិចត្រូនិច នៅប្រទេសកម្ពុជា ។

### ឃ/ ការចងក្រងជាបណ្តាញ អ្នកជំនាញប្រើប្រាស់ និងគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច

កម្មវិធីរបស់យើងក៏មានគម្រោង រៀបចំនូវបណ្តាញចងជាក្រុមមួយ ដោយប្រមូលផ្តុំនូវស្ថាប័ន និងអ្នកមានចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់ និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច ។ បណ្តាញ ជាក្រុមនេះបង្កើតឡើង ក្នុងគោលបំណង ជំរុញអោយមានការពិភាក្សា ផ្លាស់ប្តូរចំណេះដឹង ក៏ដូចជាចែករំលែកបទពិសោធន៍ទៅវិញទៅមក អំពីការសិក្សាតាមរយៈអេឡិចត្រូនិច ក៏ដូចជាបញ្ហាផ្សេងៗ ទាក់ទងនឹងវិស័យអប់រំ នៅប្រទេសកម្ពុជា ។

elearning@lists.open.org.kh គឺជាបញ្ជីសំបុត្ររួម ដែលបានបង្កើតឡើងសំរាប់ជំរុញការពិភាក្សា និងការបញ្ចេញមតិយោបល់ផ្សេង ៗ អំពីការសិក្សាតាមរយៈអេឡិចត្រូនិច ។ ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ ក្នុងការចូលរួមពិភាក្សាតាមរយៈ មធ្យោបាយបញ្ជីសំបុត្ររួមនេះ សូមទំនាក់ទំនងមកកាន់ក្រុមការងាររបស់យើងខ្ញុំ តាមរយៈអាសយដ្ឋានដែលផ្តល់ជូនខាងក្រោម ។

## ៣ ក្រុមគោលដៅរបស់កម្មវិធី

- ស្ថាប័នសិក្សាអប់រំនានា
- និស្សិតសាកលវិទ្យាល័យ

## ៤ កិច្ចសហការពីស្ថាប័នរបស់លោកអ្នក

ការអនុវត្តកម្មវិធីនេះ ផ្តល់នូវចំណេះដឹងអំពី ការគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិច ដល់ស្ថាប័នសិក្សាអប់រំនានា ក្នុងប្រទេសកម្ពុជា និងផ្តល់ជូននូវការពិគ្រោះយោបល់ផ្សេងៗ អំពីការរៀបចំ និងការដាក់អោយប្រើនូវការសិក្សាតាមរយៈអេឡិចត្រូនិច ដល់ស្ថាប័នសិក្សាអប់រំទាំងនោះ ។ ក្នុងន័យនេះ អង្គការ

សុំធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នរបស់លោកអ្នក ក្នុងការសិក្សានូវតំរូវការផ្សេងៗរបស់ស្ថាប័នលោកអ្នក ដើម្បីរៀបចំប្រព័ន្ធការសិក្សាតាមរយៈអេឡិចត្រូនិច និងផ្តល់ការកសាងសមត្ថភាពធនធានមនុស្សក្នុងការប្រើប្រាស់ និងការគ្រប់គ្រង ការសិក្សាតាមរយៈអេឡិចត្រូនិច

រាល់ចំងល់ និងព័ត៌មានផ្សេងៗ អំពីកម្មវិធីការសិក្សាតាមរយៈអេឡិចត្រូនិច សូមទំនាក់ទំនង ៖

កញ្ញា គង់ ស៊ីដារតន៍ អ្នកសំរបសំរួលគម្រោង
អង្គការវិទ្យាស្ថានបើកទូលាយ
ផ្ទះលេខ ១៩ ផ្លូវលេខ ៣៧៩ (ទល់មុខសាលាសង្កាត់ទួលស្វាយព្រៃទី១)
សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន
ប្រអប់សំបុត្រ ១៥៥២
ទូរស័ព្ទលេខ៖ ០២៣ ២២៤៨២១
សារអេឡិចត្រូនិច៖ da@open.org.kh
គេហទំព័ររបស់អង្គការ៖ www.open.org.kh

## ៥ អំពីការជួយឧបត្ថម្ភ គាំទ្រគម្រោង

កម្មវិធីនេះទទួលបាន ជំនួយឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអេស្ប៉ាញ Spanish International Cooperation Agency – AECI - និងជំនួយបច្ចេកទេសពី International Capacity Building Germany – InWent - នៃប្រទេសអាល្លឺម៉ង់ ។

ភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧
អង្គការវិទ្យាស្ថានបើកទូលាយ